# ១៥- អ្នកតាមហេសក្ខ ឬ អ្នកតាមាតគិត

ប្រជុំរឿងព្រេងខ្មែរភាគ ៨ ពីទំព័រទី ៨៩ – ៩៤

---

ឯកសារនេះ សេចក្ដីដើមជាភាសាលាវ អ្នកសរសេរឈ្មោះ ស៊ីង ភួយ ជាតិលាវ នៅស្រុកវ៉ឺនស័យ ខែត្រស្ទឹងត្រែង អាយុ ៧០ ឆ្នាំ ដែលមានសេចក្ដីបកប្រែ ដូចតទៅ ៖

នៅសង្កាត់វ៉ឺនស័យ មានអ្នកតាមួយឈ្មោះ ម៉ហេសក្ខ ។ អ្នកភូមិទាំងឡាយក្នុងសង្កាត់នេះ លើកទុកជាអ្នកខ្លាំងពូកែ ជាវត្ថុសក្ដិសិទ្ធិមួយ អាចនឹងផ្ដល់សេចក្ដីដល់បណ្ដាជនទាំងអស់បាន ។ រឿងរ៉ាងខាងដើមថា កាលដែលទឹកដីវ៉ឺនស័យ នៅជាចំណុះស្រុកថៃឡង់ដ៍នៅឡើយ នោះមាននាម៉ឺនលាវម្នាក់ដែលរាជការចាត់ឲ្យទៅត្រួតត្រាស្រុកនោះ ក៏បានអញ្ជើញអ្នកតា ម៉ហាសក្ខនេះ មកតាមខ្លួនផង ដើម្បីជាទីពឹង បានឆ្លាក់ឈើធ្វើជារូបតំណាងអ្នកតា ហើយតម្កល់ទុកលើអាស្រម ១ ក្រោមដើមផ្ចិត នៅចម្ងាយពីក្រុងវ៉ឺនស័យចំនួន ១ គីឡូម៉ែត្រ ។ កាលបើបានឃើញនាម៉ឺនលាវនោះ គោរពប្រណិប័តន៍បន់ស្រន់អ្នកតានោះទៅ បានសេចក្ដីសុខដូចសេចក្ដីប្រាថ្នា អ្នកស្រុកក៏ស្រុះស្រួលទទួលស្គាល់អ្នកតានោះតាមតមក ថាជាអ្នកតាដែលឫទ្ធានុភាពខ្លាំងពូកែ ។ ឯអ្នកតានោះកាលជាន់ដើម មានប្រកាន់រូបស្ត្រីម្នាក់ឈ្មោះនាងប៊ូ ធ្វើជាស្មិងដាច់មុខសម្រាប់តែខ្លួននោះម្នាក់ឯង ឥតមានខ្មោចបិសាចឯណាដទៃក្រៅទៀត មកសណ្ឋិតលើរូបនាងប៊ូបានឡើយ ។ កិច្ចដែលត្រូវគោរព និងត្រូវរៀបតង្វាយថ្វាយអ្នកតានោះ អ្នកស្រុកប្រព្រឹត្តធ្វើតាមតែពាក្យរូបសម្មឹងបង្គាប់ គឺមានថ្វាយ ជ្រូក មាន់ ទា ស្រា បាយ និង ទៀនធូប ។ តង្វាយបែបនេះ មិនមានកំណត់កាលវេលាទេ ស្រេចនៅមានការដែលគួរបន់ ឬ គួរថ្វាយ ។

ក្នុង ១ ឆ្នាំម្ដង អ្នកស្រុកត្រូវប្រជុំគ្នារៀបធ្វើពិធី ហៅថាបុណ្យឡើងអ្នកតា ។ បុណ្យនេះទម្លាប់ធ្វើតែនៅពិសាខ មានកំណត់ពេល ១ ថ្ងៃ ១ យប់ នៅទីខ្ទមអ្នកតានោះតែម្ដង ។ ក្រៅពីតង្វាយដូចបានរៀបរាប់ខាងលើនោះ នៅមានលេងភ្លេងដូរ្យតន្ត្រី ច្រៀងរាំ និងមានអុំទូកប្រណាំងថ្វាយអ្នកតានោះផង រៀងរាល់ឆ្នាំខានមិនបានជាដាច់ខាត បើខានមិនបានសុខទេ ។ អ្នកតានោះសព្វថ្ងៃ គេរើទីកន្លែងលើកទៅធ្វើខ្ទមឥដ្ឋប្រក់ក្បឿងនៅប្របវត្តវ៉ឺនស័យ ។ ចិន-យួនដែលស្រុកវ៉ឺនស័យទាំងប៉ុន្មាន ជឿជាក់ចំពោះអ្នកតានេះណាស់ តែងនាំគ្នាយកតង្វាយទៅថ្វាយជាប្រក្រតី ។ ប្រវត្តិអ្នកតា តាមដំណឹងថា នៅនគរឈ្មោះកោសុី ស្ដេចមួយព្រះអង្គគ្រងរាជសម្បត្តិ ព្រះនាមព្រះបាទចាក់គីមហាហង្ស ។ សម័យថ្ងៃមួយ នៅក្នុងខែមាឃ ស្ដេចអង្គនោះឯងទ្រង់ភ្នកព្រះរាជហឫទ័យចង់ស្ដេចទៅប្រពាតព្រៃ ក៏ចាត់ពួកកងសេនាមាត្យចំនួន ៨ រូប ឲ្យហែហាមអមស្ដេចទៅ នាំយកទាំងមាន់ផ្ទាក់ ៤ ទៅជាមួយផង ដើម្បីនឹងក្រសាលទាក់មាន់ព្រៃ ។ លុះបានដល់ព្រៃហើយ វេលាដែលស្ដេចកំពុងប្រពាតព្រៃនោះ ក៏ត្រូវវង្វេងព្រៃ ស្ដេចក៏ទ្រង់សុបិនឃើញស្រីក្រមុំម្នាក់ មានរូបល្អល្អះឆើតឆាយយ៉ាងក្រៃលែង ឡើងមកពីមហាបាតាលនៃមហាសាគរ ទ្រង់មានព្រះរាជហឫទ័យប្រតិព័ទ្ធស្ត្រីនោះក្រៃពេក ក៏មានព្រះបន្ទូលឲ្យអាមាត្យមុជទឹកចុះទៅតាមមើល ។ លុះមុជតាមទៅបានដល់នគរនាង ឃើញនគរ

ធំសម្បើមណាស់ ហើយល្អចម្លែកអស្ចារ្យ គឺនគរស្តេចកុម្ភណ្ឌ ។ ព្រះអង្គមានបុត្រដល់ទៅ ៣ អង្គគឺ ឈ្មោះគម្ពីរ ១ នាងតែងអន ១ និងកឡ៉ាកាន់ ១ ។ ឃើញរូបនាងនឹងនគរស្តេចជាឪពុកជាក់លាក់ហើយ អាមាត្យជាបម្រើត្រឡប់មកទូលស្តេចវិញតាមដំណើរ ។ លុះអរុណោទ័យឡើងកាលណា ទ្រង់ក៏រកឃើញផ្លូវវិលមកកាន់នគរវិញ រួចទើបចាត់ចែងរៀបចំព័ស្តុភារបណ្ណាការ ទៅស្តីដណ្តឹងនាងតែងអនមកធ្វើជាអគ្គមហេសីបានដូចសេចក្តីប្រាថ្នា ។ ឯស្តេចកុម្ភណ្ឌនោះ ជាតិជាក្រពើ មានកូនប្រុស ២ នាក់ក៏ជាក្រពើ លើកលែងតែកូនស្រី គឺនាងតែងអនមួយខុសពីគេ កើតមកជាមនុស្ស ។

ក្រោយដែលនាងតែងអន បានមកធ្វើជាអគ្គមហេសីស្តេចចាក់គីមហាហង្សហើយ ស្រាប់តែមានឈ្មោះនាងវ៉ៃកា នៅនគរជាមួយស្តេចនោះ នាំកូនក្រមុំរបស់ខ្លួន ៥ នាក់ មកថ្វាយស្តេចចាក់គីមហាហង្ស ធ្វើជាអគ្គមហេសីបន្តបន្ទាប់មកទៀត ។

លុះនាងតែងអនមានគភ៌គ្រប់ខែកាលណា ក៏ប្រសូតិព្រះរាជបុត្រនៅក្នុងចំណោមអគ្គមហេសីចុងទាំង ៥ រូប នាងទាំង ៥ នោះមានសេចក្តីបារម្ភ ខ្លាចក្រែងបុត្រនាងតែងអន មានព្រេងសំណាងជាងកូនខ្លួន ក៏តាំងនាំគ្នារួមគំនិតក្បត់ រកឧបាយកល យកកូននាងតែងអនទៅកប់ចោល យកកូនក្រពើមកដាក់ជំនួសឲ្យនាងវិញ ហើយនាំគ្នាទៅទូលស្តេចជាស្វាមីថា: នាងតែងអនជាស្រីចង្រៃកើតកូនមកជាសត្វក្រពើ ហើយប្តឹងទូលបង្ខុសថា ដោយហេតុតែនាងតែងអន ចូលចិត្តតែទៅលេងទឹក ទើបកើតកូនមកជាសត្វក្រពើ ។ ស្តេចចាក់គីមហាហង្សទ្រង់សណ្តាប់រឿងមិនពិតដូច្នេះ ក៏ពុំបានពិចារណាសាកសួររកខុសត្រូវឡើយ ទ្រង់ក៏ក្រេវក្រោធបង្គាប់ឲ្យយកនាងតែងអនទៅបំបរបង់ ។ ឯនាងតែងអន កាលបើបានទទួលផលកម្មដូច្នេះហើយ ក៏នឹកភ្នក់មាតាបិតានិងបងប្អូនរបស់នាង ហើយនាងនឹកសង្ឃឹមថា បើនាងបានទៅដល់នគរកាលណា នាងនឹងសុំឲ្យបងដែលជាសត្វក្រពើឈ្មោះគម្ពីរ មកជួយដោះទុក្ខធុរៈនាង ។ លុះបានទៅដល់នគរ នាងរៀបរាប់ទូលព្រះបិតានិងបងតាមដំណើរ ពេលនោះចៅគម្ពីរជាបងក៏ឆ្លើយតបវិញថា: វេលានេះ បងនឹងជួយដោះទុក្ខធុរៈប្អូនមិនទាន់បានទេ ព្រោះយើងមិនទាន់ចេះវិជ្ជាការអ្វីសោះ ក៏បបួលនាងតែងអនទៅរករៀនមន្តវិជ្ជាការ ។ គម្ពីរឲ្យប្អូនស្រីជិះលើខ្នង ហើយហែលធ្វើដំណើរទៅ ដោយធ្វើដំណើរឆ្ងាយពេក ការហត់នឿយខ្លាំងក៏បណ្តាលឲ្យស្លាប់ទាំងពីរនាក់បងប្អូននោះទៅ ។ ពេលនោះក៏ក្តៅទៅដល់ព្រះឥន្ទ្រ។ រមិលមើលមកឃើញដូច្នេះ ចាត់ឲ្យព្រះវិស្សកម្មទេវបុត្ត មកប្រោះបងប្អូនទាំងពីរនាក់រស់ឡើងវិញ ទើបនិម្មិតជាសាលាមួយឲ្យនៅរក្សាសីលក្នុងទីនោះ ។ តមកមានយក្សមួយឈ្មោះ ហាត់ចាក់ នៅនគរ ណានថាត់ផាន មកលេងព្រៃ ប្រទះឃើញនាងតែងអន មានរូបល្អស្អាត ក៏ចាប់យកនាងទៅធ្វើជាភីលៀងកូនស្រីរបស់វា ដែលរើសបានពីក្នុងផ្កា ។

និយាយពីបុត្រនាងតែងអន ដែលអគ្គមហេសីចុងទាំង ៥ នាក់ យកទៅកប់ចោលក្នុងដីនោះ បណ្តាលឲ្យក្តៅដល់ទេវតាមួយអង្គឈ្មោះនាងទេពជាលីឡា ទេវតានោះក៏ចុះមកកកាយដី យកទារកនោះទៅចិញ្ចឹមបីបាច់ថែរក្សា ឲ្យបរិភោគសុទ្ធសឹងអាហារទិព្វ ។ នាងទេពជាលីឡា បានហៅខ្មោចមួយ ដែលនៅអាស្រ័យក្នុងភូមិស្រុកនោះ ឈ្មោះ "មាតតាគិត" ឲ្យមកនៅជាមួយ ជួយបីបាច់រក្សាកុមារនោះដូចភីលៀង ។ លុះកុមារចំរើនអាយុធំឡើង មានវិស្សកម្មទេវបុត្តមកនិយាយប្រាប់កុមារថា: "ព្រះមាតារបស់កុមារឯងគឺ ព្រះនាងតែងអនឯណោះទេ សព្វថ្ងៃនាងត្រូវយក្សចាប់យកទៅរក្សាទុក នៅឯនគរណានថាត់ផានឯណោះ ដូច្នេះគប្បីកុមារទៅយកមាតាឲ្យឆាប់" ។

បានដំណឹងដូច្នោះ កុមារក៏នាំខ្មោចជាភីលៀងរបស់ខ្លួននោះ ទៅតាមរកព្រះមាតា បានច្បាំងនឹងយក្ស ដណ្តើមយកនាងតែងអនវិលទៅនគរវិញ ។ លុះបានដល់នគរហើយ បានសេចក្តីសុខសប្បាយ កុមារក៏ប្រាប់ប្រាមបណ្តារាស្ត្រទាំងអស់ ឲ្យគោរពរាប់អានខ្មោចដែលជាភីលៀងរបស់ខ្លួនឈ្មោះ "មាតគិត" ផង ព្រោះមាតគិតនេះ បានជួយដោះទុក្ខធុរៈខ្លួន ។ ចាប់តាំងពីពេលនោះមក បណ្តារាស្ត្រក៏ទទួលស្គាល់ "មាតគិត" នេះថា ជាអ្នកសេចក្តីសុខឲ្យខ្លួន ក៏នាំគ្នាគោរពបូជា ថែរក្សាផ្តល់ម្ហូបចំណីៈ គោ ក្របី ជ្រូក មាន់ ទា ស្រា បាយ ឲ្យបរិភោគជាប្រក្រតី ។ ខ្មោចមាតគិតនោះហើយ ដែលអ្នកស្រុកសម្គាល់ថា ជាអ្នកតារក្សាស្រុក រហូតមកដល់សព្វថ្ងៃនេះ ហៅថាអ្នកតាមហេសក្ខ ។